ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

និយ័តករធានារ៉ាប់រងកម្ពុជា

លេខ ០១១ ន.ធ.ក./សណន

# សេចក្តីណែនាំ

## ស្តីពី

## គណនីសាច់ប្រាក់ធានាសាធនភាពតម្រូវរបស់ក្រុមហ៊ុនធានារ៉ាប់រង

អនុលោមតាមច្បាប់ស្តីពីការធានារ៉ាប់រង នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨១៤/០២១ ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៤, អនុក្រឹត្យលេខ ២៧៥ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការធានារ៉ាប់រង និងប្រកាសលេខ ០៦១ អ.ស.ហ.ប្រក ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២ ស្តីពីការកំណត់កម្រិតសាធនភាពសម្រាប់ក្រុមហ៊ុនធានារ៉ាប់រង និងដើម្បីធានាបាននូវប្រសិទ្ធភាពនៃការគ្រប់គ្រង តាមដាន និងត្រួតពិនិត្យស្ថានភាពហិរញ្ញវត្ថុក្រុមហ៊ុនធានារ៉ាប់រងដែលកំពុងធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា **និយ័តករធានារ៉ាប់រងកម្ពុជា** សូមធ្វើការណែនាំដូចតទៅ÷ ក្រុមហ៊ុនធានារ៉ាប់រងទូទៅ ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ក្រុមហ៊ុនធានារ៉ាប់រងបន្ត និងក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច ត្រូវកំណត់ **ចំនួន និងលេខគណនីសាច់ប្រាក់ធានាសាធនភាពតម្រូវរបស់ក្រុមហ៊ុន** នៅធនាគារពាណិជ្ជឱ្យបានច្បាស់លាស់។ គណនីទាំងនេះ មិនត្រូវបានអនុញ្ញាតឱ្យផ្លាស់ប្តូរទេ លុះត្រាតែមានការអនុញ្ញាតជាមុនពី **និយ័តករធានារ៉ាប់រងកម្ពុជា** ហើយ ក៏ជាកម្មវត្ថុនៃការរាយការណ៍មកនិយ័តករធ្វើការតាមដានជាប្រចាំខែ អនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

ក្រុមហ៊ុនធានារ៉ាប់រងទូទៅ ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ក្រុមហ៊ុនធានារ៉ាប់រងបន្ត និងក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច ត្រូវអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់ប្រកបដោយស្មារតីទទួលខុសត្រូវចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។ ក្នុងករណីមិនអនុវត្តតាមការណែនាំនេះ ក្រុមហ៊ុននឹងទទួលទោសតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

ថ្ងៃព្រហស្បតិ៍ ១០រោច ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែធ្នូ គ.ស.២០២៣

**អគ្គនាយក**

**និយ័តករធានារ៉ាប់រងកម្ពុជា**

**ប៊ូ ច័ន្ទភិរុំ**

**ចម្លងជូន÷**

- អគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- ឯកសារ-កាលប្បវត្តិ

អគារលេខ ១៦៨ F (ជាន់ទី៦) ផ្លូវ ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កម្ពុជា
Building #168 F (6th Floor), St. 598, Sangkat Chraing Chamres 1,
Khan Russey Keo, Phnom Penh, Cambodia.
071 258 0896
gad@irc.gov.kh
www.irc.gov.kh